SSWAHTU: 801
KHMER
NOVEMBER 2007

# SSWAHS

# សន្លឹកព័ត៌មានសំរាប់មាតា ចំពោះការបំបៅទឹកដោះគោបន្ថែម

# Mother's Information Sheet For Complementary Feeding

ក្រុមប្រឹក្សាជាតិលើការស្រាវជ្រាវផ្នែកសុខភាព និងវេជ្ជសាស្ត្រនៃប្រទេសអូស្ត្រាលី (National Health and Medical Research Council of Australia) ហើយនិងគោលការណ៍បំបៅកូននឹងទឹកដោះម្តាយ រដ្ឋញូវសៅវ៉េល (NSW State Breastfeeding Policy) បញ្ជាក់ថាទម្លាប់នៃការបំបៅទឹកដោះគោបន្ថែម មិនគួររាប់បញ្ចូលទារកទាំងឡាយណាដែលទទួល ឬបៅទឹកដោះម្តាយគ្រប់ពេលនោះទេ ដោយព្រោះមូលហេតុដូចតទៅនេះ:

- ម្សៅទឹកដោះគោនាំឲ្យមានការបង្អាក់ទៅដល់ការការពារទប់ទល់នឹងមេរោគ ដែលទឹកដោះម្តាយអាចផ្តល់សំរាប់ទារករបស់អ្នក។
- ការបំបៅកូននឹងទឹកដោះម្តាយមានដំណើរការស្របទៅតាមការផ្គត់ផ្គង់ និងតំរូវការ។ ប្រសិនបើមានការខកខាន ឬក៏ការប្រើម្សៅទឹកដោះគោ នោះដោះអាចបង្កើតទឹកដោះតិចជាងធម្មតា។
- ពេលណាមិនបានប្របាច់យកទឹកដោះចេញពីដោះទេ ដោះអាចបណ្តាលទៅជាឈឺចាប់ ហើយឈប់បង្កើតទឹកដោះ។
- ទារករបស់អ្នកអាចទាស់ទៅនឹងជាតិប្រូតេអ៊ីន ដែលមាននៅក្នុងម្សៅទឹកដោះគោ។
- តំរូវការចំពោះការបំបៅកូននឹងទឹកដោះម្តាយ ធ្វើឲ្យទារកមិនឆាប់ងាយកើតជម្ងឺខាន់លឿង។
- ការស្រាវជ្រាវបង្ហាញឲ្យឃើញថា ការផ្តល់ទារកនូវទឹកដោះគោបន្ថែមនៅមន្ទីរពេទ្យ ទាក់ទិនយ៉ាងខ្លាំងទៅនឹងលទ្ធភាពនៃការធ្លាក់ចុះថយក្នុងការបំបៅកូននឹងទឹកដោះម្តាយជាបន្តទៀត ក្រោយពីបានចាកចេញពីមន្ទីរពេទ្យ។

## សំណើយ៉ាងមាំទាំចំពោះមាតា:

- ប្របាច់យកទឹកដោះឲ្យបានទៀងទាត់ ដើម្បីរក្សាការផ្គត់ផ្គង់នូវបរិមាណទឹកដោះ ហើយនិងការបង្ការមិនឲ្យដោះឡើងហើម។
- ប្រើទឹកដោះប្របាច់ ពេលណាអាចធ្វើទៅបាន ដើម្បីកាត់បន្ថយឲ្យមានតិចបំផុតនូវភាពដែលអាចកើតមាននៃការទាស់ទៅនឹងជាតិប្រូតេអ៊ីននៅក្នុងទឹកដោះគោ។

(យកលំនាំតាមគោលការណ៍ណែនាំរបស់ NH&MRC លើការបំបៅទារកសំរាប់ភ្នាក់ងារសុខាភិបាល ឆ្នាំ២០០៣ ទំព័រ ៤៤៣ និង John Hunter ការអនុញ្ញាតយល់ព្រមពីមន្ទីរពេទ្យដើម្បីបំបៅទឹកដោះគោបន្ថែម)